ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ៣៥នាក់ និងមានករណីជាសះស្បើយ ចំនួន ០២នាក់ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖** គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ មានដូចតារាងខាងក្រោមនេះ ៖

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៤០២ | ១០៩ | ២៩៣ | អ្នកឆ្លងថ្មី៖ **០៤នាក់** |
| | ១.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៩០ | ៦៩ | ២១ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | ១.៣. ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ | ៧៦ | ៣៩ | ៣៧ | អ្នកឆ្លងថ្មី៖ **៣១នាក់** |
| | **សរុបអ្នកមានវីរុសកូវីដ-១៩** | **៥៦៨** | **២១៧** | **៣៥១** | អ្នកឆ្លងថ្មី៖ **៣៥នាក់** |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣៨៧ | ១០០ | ២៨៧ | អ្នកជាសះស្បើយថ្មី៖**០២នាក់** |
| | ២.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៨៨ | ៦៨ | ២០ | អ្នកជាសះស្បើយថ្មី៖០នាក់ |
| | **សរុបអ្នកព្យាបាលជាសះស្បើយ** | **៤៧៥** | **១៦៨** | **៣០៧** | អ្នកជាសះស្បើយថ្មី៖**០២នាក់** |
| ៣. | **អ្នកកំពុងសម្រាកព្យាបាល ៖** | | | | |
| | ៣.១មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន | ៤៤ | ២៥ | ១៩ | |
| | ៣.២. មន្ទីរពេទ្យបង្អែក ខេត្តប៉ៃលិន | ០១ | ០១ | ០ | |
| | ៣.៣.មន្ទីរពេទ្យបង្អែក ខេត្តបន្ទាយមានជ័យ | ០១ | ០ | ០១ | |
| | ៣.៤. មន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបង | ០ | ០ | ០ | |
| | ៣.៥.មន្ទីរពេទ្យបង្អែក ខេត្តឧត្តរមានជ័យ | ០ | ០ | ០ | |
| | ៣.៦.មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ៤៤ | ២១ | ២៣ | |
| | ៣.៧. មណ្ឌលសុខភាពចាក់អង្រែ | ០៣ | ០២ | ០១ | |
| | **សរុបអ្នកកំពុងសម្រាកព្យាបាល** | **៩៣** | **៤៩** | **៤៤** | |

**សូមកត់សម្គាល់ថា៖ ក្រសួងសូមធ្វើការកែតម្រូវចំណុចមួយចំនួន មានដូចខាងក្រោម៖**

-សូមកែតម្រូវត្រង់ចំនុចករណីវិជ្ជមាន ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ដែលបានចេញផ្សាយកាលពី



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

ថ្ងៃទី២០ខែកុម្ភៈឆ្នាំ២០២១ ចំនួន៨៣នាក់ មកចំនួន៨៥នាក់វិញដែលជាចំនួនត្រឹមត្រូវនៅថ្ងៃទី២១ខែកុម្ភៈឆ្នាំ២០២១។

-សូមកែតម្រូវព័ត៌មានអ្នកជំងឺ ស្ត្រីជនជាតិឈីលី អាយុ ៣០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ ដែលបានចេញផ្សាយកាលពីថ្ងៃទី១៩ មកជាជនជាតិចិនវិញ។

-មានអ្នកជំងឺចំនួន ០៦នាក់ បានប្តូរពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មកសម្រាកព្យាបាលនៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន។

-មានអ្នកជំងឺចំនួន ០២នាក់ បានប្តូរពីមណ្ឌលសុខភាពចាក់អង្រែ មកសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**២. ព័ត៌មានប្រចាំថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១**

**ក. មានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ សរុបចំនួន ៣៥នាក់**

**ក.១. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ០៤នាក់ ដែលជាអ្នកដំណើរចូលមកកម្ពុជា (មិនមែនជាពលករធ្វើដំណើរមកពីប្រទេសថៃ)**

- បុរសជនជាតិខ្មែរ អាយុ ៨៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសហ្កាណា បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជានៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១។ លទ្ធផលធ្វើតេស្តវត្ថុសំណាកលើកទី០២ របស់បុរសរូបនេះ ផ្តល់ដោយវិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល គឺ វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្នអ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

**សូមកត់សម្គាល់ថា៖** អ្នកដំណើរតាមយន្តហោះជាមួយអ្នកជំងឺខាងលើ សរុបមានចំនួន ៤១នាក់ ដែលនៅក្នុងចំនួននេះមាន បុគ្គលខាងលើនេះផងដែរ។ រីឯ អ្នកដំណើរចំនួន ៤០នាក់ ដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ នោះ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅសណ្ឋាគារមួយក្នុង រាជធានីភ្នំពេញ ចំនួន ០២នាក់ សណ្ឋាគារមួយទៀត ចំនួន ១៥នាក់ សណ្ឋាគារមួយទៀតចំនួន ០២នាក់ និងសណ្ឋាគារមួយផ្សេងទៀត ចំនួន ២១នាក់។

- បុរសជនជាតិចិន អាយុ ៣៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សណ្ឋាគារមួយក្នុង រាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសចិន តាមជើងហោះហើរ មកដល់កម្ពុជានៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១។

- ស្ត្រីជនជាតិចិន អាយុ ២៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សណ្ឋាគារមួយក្នុង រាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសចិន តាមជើងហោះហើរ មកដល់កម្ពុជានៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១។

- បុរសជនជាតិចិន អាយុ ៤០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សណ្ឋាគារមួយក្នុង រាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសចិន តាមជើងហោះហើរ មកដល់កម្ពុជានៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១។

**សូមកត់សម្គាល់ថា៖** លទ្ធផលធ្វើតេស្តវត្ថុសំណាកលើកទី០២ របស់បុគ្គលទាំង ០៣រូបខាងលើនេះ ផ្តល់ដោយវិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល គឺ វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្នអ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។

អ្នកដំណើរតាមយន្តហោះជាមួយអ្នកជំងឺខាងលើ សរុបមានចំនួន ០៦នាក់ ដែលនៅក្នុងចំនួននេះមាន បុគ្គលខាងលើនេះផងដែរ។ រីឯ អ្នកដំណើរចំនួន ០៣នាក់ ដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ នោះ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅសណ្ឋាគារ សុខាភ្នំពេញ ចំនួន ០៣នាក់។

**ក.២ ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ៣១នាក់ ដែលជាអ្នកពាក់ព័ន្ធទៅព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ**

-បុរសជនជាតិខ្មែរអាយុ ៣៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសង្កាត់ផ្សារធំថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-បុរសជនជាតិខ្មែរអាយុ ៣៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសង្កាត់ស្រះចក ខណ្ឌដូនពេញរាជធានីភ្នំពេញ។
- បុរសជនជាតិខ្មែរ អាយុ ៤៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។
-បុរសជនជាតិខ្មែរអាយុ ៣៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវរាជធានីភ្នំពេញ។
- បុរសជនជាតិខ្មែរ អាយុ ៣៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។
- ស្ត្រីជនជាតិខ្មែរ អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សណ្ឋាគារមួយក្នុង រាជធានីភ្នំពេញ។
-កុមារជនជាតិខ្មែរអាយុ ១១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់គោកឃ្លាំងខណ្ឌសែនសុខរាជធានីភ្នំពេញ។
-ស្ត្រីជនជាតិខ្មែរអាយុ ៤០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់គោកឃ្លាំងខណ្ឌសែនសុខរាជធានីភ្នំពេញ។
- ស្ត្រីជនជាតិខ្មែរ អាយុ ៥១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។
-ស្ត្រីជនជាតិខ្មែរអាយុ ៧១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់គោកឃ្លាំងខណ្ឌសែនសុខរាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៣០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ ១៧នាក់ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន។

- ស្ត្រីជនជាតិចិន អាយុ ៣០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៣៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៤១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សណ្ឋាគារមួយក្នុង រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សណ្ឋាគារមួយក្នុង រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៣៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៣០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិកូរ៉េ អាយុ ៣៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ ១៣នាក់ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

- ស្ត្រីជនជាតិខ្មែរ អាយុ ២៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ ០១នាក់ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

**ខ. មានករណីជាសះស្បើយ ៖ ចំនួន ០២នាក់ ដែលជាអ្នកដំណើរចូលមកកម្ពុជា (មិនមែនជាពលករធ្វើដំណើរមកពីប្រទេសថៃ)**

- បុរសជនជាតិឥណ្ឌា អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅរាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌា បន្តជើងហោះហើរនៅប្រទេសសិង្ហបុរី មកដល់កម្ពុជានៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១។
- ស្ត្រីជនជាតិឥណ្ឌា អាយុ ២២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅរាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌា បន្តជើងហោះហើរនៅប្រទេសសិង្ហបុរី មកដល់កម្ពុជានៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១។

**សូមកត់សម្គាល់ថា៖** បុគ្គលទាំង ០២រូបខាងលើនេះត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន រាជធានីភ្នំពេញ។

**៣. សេចក្តីអំពាវនាវក្រើនរំលឹក ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ៖**

ក្រសួងសុខាភិបាល សូមធ្វើការអំពាវនាវ និងក្រើនរំលឹកសារជាថ្មីម្តងទៀត សូមបងប្អូនប្រជាពលរដ្ឋទាំងអស់នៅទូទាំងប្រទេស និងជាពិសេសអ្នករស់នៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល ត្រូវប្រកាន់យកនូវការប្រុងប្រយ័ត្នខ្លួនជាប់ជានិច្ច គ្រប់គ្រងក្រុមគ្រួសារឱ្យបានល្អ និងចូលរួមអនុវត្តវិធានការការពារខ្លួនឱ្យបានខ្ជាប់ខ្ជួនគ្រប់ៗគ្នា តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានថ្លែងនៅក្នុងសន្និសីទសារព័ត៌មាននាព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១។

តាមការស៊ើបអង្កេតស្រាវជ្រាវ បានបង្ហាញថា ស្ថានភាពនៃការចម្លងក្នុងសហគមន៍នាពេលនេះ មានលក្ខណៈធំជាង និងស្មុគស្មាញជាងព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា ហើយវិធានការ និងអន្តរាគមន៍នានា បានដាក់ចេញជាបណ្តើរៗ គឺអាស្រ័យទៅតាមស្ថានភាពនៃការរកឃើញវត្តមានវីរុសកូវីដ-១៩ នៅតាមទីតាំងនីមួយៗ (Localized interventions) ដើម្បីទប់ស្កាត់ការចម្លងបន្តនូវវីរុសកូវីដ-១៩ នៅក្នុងសហគមន៍ទ្រង់ទ្រាយធំផេង។ តារាងខាងក្រោមនេះ គឺជាទីតាំងដែលបានបិទជាបណ្តោះអាសន្ន ហើយក្រសួងសុខាភិបាល សូមធ្វើការអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ សហការសាមគ្គីភាពគ្នា ជួយគ្នាទៅវិញទៅមក ចូលរួមអនុវត្តន៍ដោយម៉ឺងម៉ាត់នូវការដាក់ចេញនូវវិធានការសុខាភិបាល ដែលមានដូចតទៅ៖

**ក. បុគ្គលដែលធ្លាប់បានចេញចូលទីតាំងខាងលើ** ពីថ្ងៃទី០៦ ដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ឬបុគ្គលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬដឹងថាខ្លួនជាអ្នកប៉ះពាល់ជាមួយអ្នកមានវីរុសកូវីដ-១៩ ត្រូវមានភាពស្មោះត្រង់ មិនលាក់លៀម និងស្ម័គ្រចិត្តមកធ្វើតេស្តរកមេរោគកូវីដ-១៩ នៅរៀងរាល់ម៉ោងធ្វើការ សូមអញ្ជើញមកធ្វើតេស្ត យកវត្ថុសំណាកដើម្បីវិភាគរកវីរុសកូវីដ-១៩ នៅមណ្ឌលសុខភាពចាក់អង្រែនៃរាជធានីភ្នំពេញ ហើយដាក់ខ្លួននៅដាច់ដោយឡែកពីក្រុមគ្រួសារ ធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃនៅតាមផ្ទះរៀងៗខ្លួន ព្រមទាំងធ្វើការតាមដានសុខភាពជារៀងរាល់ថ្ងៃ។ ប្រសិនបើមានអាការៈមិនស្រួលខ្លួន ដូចជាមានឡើងកំដៅខ្លួន ក្អក ផ្តាសាយ ឈឺបំពង់ក ឬពិបាកដកដង្ហើមជាដើម សូមហៅទៅលេខទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ឬលេខទូរស័ព្ទដែលមានជូននៅខាងក្រោមនេះស្រាប់ ដើម្បីជួយអន្តរាគមន៍សុខភាពបានទាន់ពេលវេលា។

**ខ. ត្រូវចូលរួមធ្វើចត្តាឡីស័ក**ឱ្យបានត្រឹមត្រូវ និងគ្រប់ចំនួន ១៤ថ្ងៃ តាមការណែនាំរបស់ក្រសួងសុខាភិបាល សម្រាប់អ្នកដែលសង្ស័យ ឬដែលបានប៉ះពាល់ដោយផ្ទាល់ ឬប្រយោល ជាមួយនឹងបុគ្គលដែលបានរកឃើញថាមានវិជ្ជមានវីរុសកូវីដ-១៩។ ការធ្វើចត្តាឡីស័កនេះ ត្រូវធ្វើនៅតាមគេហដ្ឋានរៀងៗខ្លួន រីឯបុគ្គលដែលមិនមានលទ្ធភាពធ្វើចត្តាឡីស័កនៅផ្ទះរបស់ខ្លួន អាជ្ញាធរថ្នាក់ក្រោមជាតិ មានភារកិច្ចក្នុងការគ្រប់គ្រង តាមដានការអនុវត្ត និងចាត់ចែងទីកន្លែងសម្រាប់ការធ្វើចត្តាឡីស័កនេះ។

**គ. ត្រូវចូលរួមផ្តល់ព័ត៌មាន** ស្តីពីទំនាក់ទំនងផ្ទាល់ ឬប្រយោលរវាងបុគ្គល និងបុគ្គល ដែលមានការពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ដោយមិនមានការលាក់លៀម ដើម្បីឈានទៅកំណត់មុខសញ្ញាសង្ស័យថាអាចមានការឆ្លងវីរុសកូវីដ-១៩ យកវត្ថុសំណាកទៅធ្វើតេស្តរកវីរុសកូវីដ-១៩ និងត្រូវដាក់បុគ្គលនោះឱ្យនៅដាច់ដោយឡែក ដើម្បីរង់ចាំលទ្ធផលពីមន្ទីរពិសោធន៍។

**ឃ. សហការផ្តល់ព័ត៌មានជាក់លាក់ ដើម្បីឱ្យសកម្មធ្វើការរុករកស្រាវជ្រាវ** រកអ្នកដែលប៉ះពាល់ផ្ទាល់ ឬប្រយោល និងយកយកវត្ថុសំណាកទៅធ្វើតេស្តរកវីរុសកូវីដ-១៩ ព្រមទាំងដាក់អ្នកវិជ្ជមានវីរុសកូវីដ-១៩ នៅដាច់ដោយឡែក និងផ្តល់ការព្យាបាលនៅក្នុងមន្ទីរពេទ្យជូនភ្លាមៗ អាចប្រព្រឹត្តទៅបានរហ័ស ចៀសវាងការអូសបន្លាយពេលវេលាយូរ ដែលអាចបង្កគ្រោះថ្នាក់សុខភាព បណ្តាលមកពីការចម្លងវីរុសជំកាចសាហាវនេះ ដោយយើងមិនបានដឹង និងមានហានិភ័យខ្ពស់ក្នុងការចម្លងបន្តគ្នាលឿនក្នុងទ្រង់ទ្រាយធំធេង ដែលអាចបង្កស្ថានភាពពគតព្យាតអាក្រក់នៅក្នុងប្រទេសកម្ពុជា។

**ង. បើមិនចាំបាច់ សុំនៅផ្ទះ** (កុំចេញក្រៅផ្ទះ ដោយមានការប្រុងប្រយ័ត្នពីការឆ្លងបន្តគ្នានូវវីរុសកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ ដែលបម្លែងថ្មី) និងមើលការខុសត្រូវកូនចៅឱ្យបានល្អ ក្នុងពេលសកម្មភាពស្វែងរកអ្នកដែលប៉ះពាល់កំពុងតែសកម្ម។

**ច. មិនត្រូវមានការរើសអើង** ដល់អ្នកដែលរងគ្រោះឆ្លងវីរុសកូវីដ-១៩ ឬរើសអើងពូជសាសន៍ ឬរើសអើងមនុស្សតាមតំបន់ដែលមានការឆ្លងច្រើន ផ្ទុយទៅវិញ ត្រូវចេះជួយគ្នាទៅវិញទៅមក ដើម្បីរួមគ្នាបញ្ចប់នូវសភាពការណ៍ កុំឱ្យវិវត្តន៍ទៅកាន់ស្ថានភាពអាក្រក់ពេក ដែលនឹងប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។

**ឆ.** បុគ្គលគ្រប់រូប ចាំបាច់ត្រូវអនុវត្តន៍វិធានការ **៣ការពារ** (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង) និង **៣កុំ** (កុំទៅកន្លែងដែលមានមនុស្សកកកុញច្រើន កុំទៅកន្លែងដែលបិទជិតឈឹងមិនមានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក និងកុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបគ្នា នៅពេលជួបគ្នា ការធ្វើគារវកិច្ចដោយសំពះគ្នា ងក់ក្បាល ឬគ្រវីដៃ ជាដើម) គ្រប់ពេលវេលា គ្រប់កាលទេសៈ និងគ្រប់ទីកន្លែង។

**ទីតាំងពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១**

| ល.រ | ទីតាំង | អាសយដ្ឋាន | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ផ្ទះលេខ | ផ្លូវ | សង្កាត់ | ខណ្ឌ | |
| ១ | ក្លឹប N8 | | ២១៧ កែង ២៨៦ | ទួលស្វាយព្រៃទី២ | បឹងកេងកង | បានបិទ |
| ២ | Casa By Meridian | កោះពេជ្រ | St. Harvard | ទន្លេបាសាក់ | ចំការមន | បានបិទ |
| ៣ | Le Gong Guan Hotel | ១២៦ | ១៧២ | ផ្សារថ្មីទី៣ | ដូនពេញ | បានបិទ |
| ៤ | City Comfort | អគារ២៨ | ១១៥ | បឹងព្រលឹត | ៧មករា | បានបិទ |
| ៥ | The Bridge | | ៧៨ | ទន្លេបាសាក់ | ចំការមន | បានបិទ |
| ៦ | The Point Service Apartment | ៦៣ | ២១៩ | ផ្សារដើមគ | ទួលគោក | បានបិទ |
| ៧ | Mekong Street | ៨ | ទន្លេមេគង្គ | ជ្រោយចង្វារ | ជ្រោយចង្វារ | បានបិទ |
| ៨ | Pent House Apartment | មុខ Aeon1 | សុធារស | ទន្លេបាសាក់ | ចំការមន | បានបិទ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | Skyline Dumex | | ១៣៤ | មិត្តភាព | ៧មករា | **បានបិទ** |
| ១០ | Somet Condoninium | | 236 | ភ្សារដ៏ | ៧មករា | **បានបិទ** |
| ១១ | Residence L Olympic | ១១៧ | ២៩២ | អូឡាំពិច | បឹងកេងកង | **បានបិទ** |
| ១២ | Prince Plazza Centre | | នរោត្តម | ទន្លេបាសាក់ | ចំការមន | **បានបិទ** |
| ១៣ | Celeste Skybar | ទល់មុខស្ទៀតែល | សុធារស | ទន្លេបាសាក់ | ចំការមន | **បានបិទ** |
| ១៤ | Diamond Twin | | កោះពេជ្រ | ទន្លេបាសាក់ | ចំការមន | **បានបិទ** |
| ១៥ | JinZun ខារ៉ាអូខេមុខព្រលាន | | ផ្លូវសហព័ន្ធរុស្ស៊ី | កាកាប | ពោធិ៍សែនជ័យ | **បានបិទ** |
| ១៦ | ក្លឹប Coco សណ្ឋាគារកណ្ដាលសួនច្បារ | | | ចតុមុខ | ដូនពេញ | **បានបិទ** |
| ១៧ | JuHao មុខហាងឆ្នេរមាស | | | ទន្លេបាសាក់ | ចំការមន | **បានបិទ** |
| ១៨ | ហាង The World | ក្រោយផ្សារបឹងត្របែក | | បឹងត្របែក | ចំការមន | **បានបិទ** |
| ១៩ | ហាច វ៉ែនមែនសិន | ក្រោយផ្សារបឹងត្របែកផ្លាហ្សា | | បឹងត្របែក | ចំការមន | **បានបិទ** |
| ២០ | ក្លឹប ១៦៨ អតីតនគរស៊ីវិទ្ធិ | កែងវត្តមហាមន្ត្រី | អគារលេខ៥៦ | អូឡាំពិច | បឹងកេងកង | **បានបិទ** |
| ២១ | Love | ក្រោយអ៊ិចូ | | បឹងកក់ | ដូនពេញ | **បានបិទ** |
| ២២ | វិទ្យាល័យហ៊ុនសែនភ្នំពេញថ្មី | ក្រោយវត្តសំពោងអណ្តែត | | ភ្នំពេញថ្មី | ទួលគោក | **បានបិទ** |
| ២៣ | សាលា SIS | អគារលេខ១៤ | ៣៣៦ | ផ្សារដើមគ | ទួលគោក | **បានបិទ** |

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ ទីតា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ ទីតា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង

និងបង្ការជំងឺឆ្លង សហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៨២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ១១កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩